


# ពូជស្រូវស្រាល "ជលសារ"




ពូជស្រូវ "**ជលសារ**" ជាស្រូវស្រាលមិនប្រកាន់រដូវដែលបានធ្វើការរំដោះ និងផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជានាឆ្នាំ ១៩៩៩។ បច្ចុប្បន្នពូជស្រូវ "**ជលសារ**" បាន នឹងកំពុងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់។

## លក្ខណៈពិសេសៗរបស់ពូជស្រូវ "ជលសារ"

ពូជស្រូវ "**ជលសារ**" ជាពូជស្រូវដែលមានអវេទរសភាពនឹងរយៈពន្លឺ (មិនប្រកាន់រដូវ) និងអាចចេញផ្កាគ្រប់ពេលវេលាដរាបណាលក្ខខណ្ឌដាំដុះអនុគ្រោះដល់ការលូតលាស់របស់វា។ អាស្រ័យដោយហេតុផលខាងលើនេះទើបពូជនេះអាចដាំដុះនៅដើមរដូវវស្សា (ដំណាំទីមួយនៃរដូវ ឬស្រូវដើមរដូវ) ក្នុងរដូវវស្សា (ដំណាំទីពីរនៃរដូវ) ចុងរដូវវស្សា និងស្រូវប្រដេញទឹក (ដំណាំចន្លោះរដូវវស្សា និងរដូវប្រាំង) និងលក្ខខណ្ឌប្រាំងស្រោចស្រព។ ពូជស្រូវ "**ជលសារ**" នេះមានអាយុកាលពី ៩៥- ១១០ ថ្ងៃ គឺចាប់ពីថ្ងៃសាបរហូតដល់ថ្ងៃប្រមូលផល។ កំពស់ដើមរបស់ពូជស្រូវ "**ជលសារ**" ប្រែប្រួលពី ៧៥ - ៩៣ ស.ម និងចំនួនដើមបែកផ្តល់ផលគឺចាប់ពី ១០- ១៥ ដើមក្នុងមួយគុម្ពអាស្រ័យទៅតាមប្រភេទដី។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី ១០០ - ១៥០ គ្រាប់ និងមានប្រវែងកួរ ២០ - ២៧ ស.ម។ រីឯទិន្នផលរបស់វាវិញ គឺអាចទទួលបានចាប់ពី ៤,០ តោនទៅ ៦,០ តោនក្នុងផ្ទៃដី ១ ហិកតា។ ពូជស្រូវ "**ជលសារ**" គឺជាពូជ ដែលធន់ទ្រាំមធ្យមទៅនឹងពពួកមមាចត្នោត។

## វិធីសាស្ត្រដាំដុះ

សម្រាប់ស្រូវសន្ទូង ចំពោះតំបន់ដែលងាយរងគ្រោះរាំងស្ងួត និងទឹកជំនន់ បរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺពី ៦០-៨០ គីឡូក្រាមក្នុងមួយហិកតា។ ចំពោះតំបន់ដែលគ្រប់គ្រងទឹកបាន បរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺពី ៣០-៤០ គីឡូក្រាមក្នុងមួយហិកតា។ ក្នុងករណីដែលគ្រាប់ពូជសុទ្ធ និងមានសុខភាពល្អ ព្រមទាំងគ្រប់គ្រងទឹកបាន និងថែទាំបានល្អ បរិមាណគ្រាប់ពូជដែលត្រូវការក្នុងមួយហិកតាគឺពី ១៥-២០ គីឡូក្រាម។ ដើម្បីឱ្យសំណាបដុះលូតលាស់ធំធាត់ល្អ គេត្រូវសាបគ្រាប់ពូជមួយគីឡូក្រាមលើផ្ទៃដីថ្នាល ១០ ម៉ែត្រការ៉េ។ ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ព្រៃ ឬកន្លែងមានភ្លើងអគ្គីសនី ដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។ ជាការល្អគួរស្ទូងសំណាបដែលមានអាយុ ១៨-២២ ថ្ងៃ ហើយក្នុងមួយគុម្ពចំនួន ២-៣ ដើម។ សម្រាប់ស្រូវពង្រួស ចំពោះតំបន់ដែលងាយរងគ្រោះរាំងស្ងួត និងទឹកជំនន់ បរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺពី ១០០-១៥០ គីឡូក្រាមក្នុងមួយហិកតា។ ចំពោះតំបន់ដែលគ្រប់គ្រងទឹកបាន និងគ្រាប់ពូជសុទ្ធ

ល្អ បរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺពី ៨០-១០០ គីឡូក្រាមក្នុងមួយហិកតា។ គួររៀបចំដីឱ្យបានល្អ និងរាបស្មើមុនស្ទូង ឬព្រួស។ ការភ្ជួររាស់គួរតែធ្វើឱ្យបាន ២-៣ សារជាការល្អប្រសើរ។ បើសិនស្រែអាចបញ្ចេញបញ្ចូលទឹកបាន បន្ទាប់ពីស្ទូង ឬព្រួសបាន ២០ ថ្ងៃ អាចបញ្ចេញទឹកឱ្យអស់ពីក្នុងស្រែ ២-៤ ថ្ងៃ រួចបញ្ចូលទឹកថ្មីវិញ។ ធ្វើរបៀបនេះ គឺដើម្បីធ្វើឱ្យស្រូវកាន់តែបែកគុម្ពល្អ។ ប៉ុន្តែពេលស្រូវបែកគុម្ពអតិបរិមា គួរបង្ហូរទឹករយៈពេលមួយអាទិត្យ ដើម្បីកុំឱ្យស្រូវដុះខ្នែងមកច្រើនទៀត។

## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីសមស្របតាមកម្រិតណែនាំ នឹងមិនបណ្តាលឱ្យមានការថយចុះ ឬបាត់បង់ក្លិន ឬគុណភាពដទៃទៀតឡើយ។ គួរដាក់ជី ២-៣ ដងក្នុងមួយវដ្តជីវិតរបស់ស្រូវដោយ:

-*បាចលើកទី១:* ទ្រាប់បាតមុនពេលស្ទូងប្រើជីធម្មជាតិពី ៥-១០ តោន/ហត និងរួមផ្សំជាមួយជីគីមីដូចមានក្នុងតារាងទី ១។ សម្រាប់ពេលវេលានៃការបាចជីបំប៉ន គឺត្រូវធ្វើឡើងនៅរយៈពេល ១៥ ថ្ងៃ (បំប៉នលើកទីមួយ) និង ៣០ថ្ងៃ (បំប៉នលើកទីពីរ ) ក្រោយពេលស្ទូង។



**តារាងទី ១** កម្រិតជីណែនាំតាមប្រភេទដី

| ប្រភេទដី | ប្រភេទជី | ទ្រាប់បាត (គក្រ/ហត) | បំប៉ន (គក្រ/ហត) លើកទី១ | បំប៉ន (គក្រ/ហត) លើកទី២ |
|---|---|---|---|---|
| ដីខ្សាច់ (ដីព្រៃខ្មែរ ប្រទះឡាង) | អ៊ុយរ៉េ | ៣១ | ៨៧ | ៦៦ |
| | ដេអាប៉េ | ៨៧ | ០ | ០ |
| | ប៉ូតាស | ១៣៣ | ០ | ០ |
| ដីល្បាយឥដ្ឋ (ដីបាកាន អូរូង ទួលសំរោង គោកត្រប់ ក្រគរ) | អ៊ុយរ៉េ | ៥២ | ១០៥ | ៧៥ |
| | ដេអាប៉េ | ១៣០ | ០ | ០ |
| | ប៉ូតាស | ៦៧ | ០ | ០ |
| ដីឥដ្ឋ (ដីកំពង់សៀម ក្បាលពោធិ កៀនស្វាយ ) | អ៊ុយរ៉េ | ៥៣ | ៨៧ | ៦៦ |
| | ដេអាប៉េ | ៣៥ | ០ | ០ |

## ការប្រមូលផល



- ត្រូវធ្វើការច្រូតកាត់នៅរវាង ៣០-៣៥ ថ្ងៃបន្ទាប់ពីស្រូវហាលផ្កាស្រុះ ឬពេលដែលប្រមាណ ៨៥ ភាគរយនៃគ្រាប់ស្រូវទុំ។
- ត្រូវហាល ២-៣ ថ្ងៃ ដើម្បីបន្ថយសំណើមនៅក្នុងគ្រាប់ឱ្យនៅ ១៤ ភាគរយមុននឹងទុកជាការល្អ។ សូមយកគ្រាប់ស្រូវមកខាំដើម្បីកំណត់ បើគ្រាប់ស្រូវនោះបាក់ គឺមានន័យថាគ្រាប់ស្រូវស្ងួតល្អអាចទុកដាក់បាន។
- គ្រាប់ពូជ ត្រូវច្រកទុកនៅក្នុងបាវក្រចៅដាច់ដោយឡែកពីគ្រាប់ស្រូវចំណីនៅកន្លែងដែលស្ងួតល្អ ហើយគ្មានការបំផ្លាញពីសត្វកណ្តុរ មាន់ ទាជាដើម។ ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ដាក់នៅលើបាវឱ្យបានត្រឹមត្រូវល្អ។
-គ្រាប់ស្រូវចំណីត្រូវទុកដាក់ក្នុងជង្រុកឱ្យបានល្អ ដោយការពារកុំឱ្យសត្វកណ្តុរ មាន់ ទា ចូលស៊ី និងមិនឱ្យទទឹក។




សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ, ទូរស័ព្ទលេខ:(៨៥៥-២៣)២១៩ ៦៩៣-៤

ទូរសារលេខ: (៨៥៥-២៣ ) ២១៩ ៨០០ ទូរអក្ខរ: cardi@cardi.org.kh វែបសាយ: www.cardi.org.kh

PBREED@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh